**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៨១...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួល ផ្លាកសញ្ញាសម្រាប់ពាក់លើមួក ផ្លាកសញ្ញាសំរាប់ថ្នាក់ឧត្តមសេនីយ៍ និងឯកសណ្ឋានការងារលេខ៤ នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ១៩៩៧ និងអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៣

* * * * * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំឯកសណ្ឋាន ផ្លាកសញ្ញា និង ទង់ជ័យនៃកងយោធពលខេមរភូមិន្ទ

-បានឃើញអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០០៣ ស្តីពីការកែសំរួលផ្លាកសញ្ញារូបហនុមានសញ្ញាកងឯកភាពឆ័ត្រយោង ឯកសណ្ឋានលេខ៤ មួកបេរេ ការស្លៀកពាក់ឯកសណ្ឋានលេខ ៤ និងសញ្ញាអត្តបញ្ជាការដ្ឋាន កងទ័ពជើងគោក ជើងទឹក ជើងអាកាស និងរូបសញ្ញាក្រសួងការពារជាតិ

- យោងសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១.-**

អនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំឯកសណ្ឋាន ផ្លាកសញ្ញា និងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ នៅមាត្រា ៥ ត្រង់ចំណុច ក អំពីរូបព្រះសង្ហារ មាត្រា ៦ ត្រង់ចំណុចទី ១ ចំណុចទី ២ អំពីសញ្ញាថ្នាក់

ឧត្តមសេនីយ៍ និងអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីការកែសម្រួលផ្លាកសញ្ញារូបហនុមាន សញ្ញាកងឯកភាពឆ័ត្រយោង ឯកសណ្ឋានការងារលេខ ៤ និងសញ្ញាអត្តបញ្ញាការកងទ័ពជើងគោក កងទ័ពជើងទឹក កងទ័ពជើងអាកាស និងរូបសញ្ញាក្រសួងការពារជាតិ នៅមាត្រា១ ត្រង់ចំណុចទី៣ អំពីឯកសណ្ឋានការងារ ត្រូវបានកែសម្រួលដូចខាងក្រោម ៖

**១-ផ្លាកសញ្ញាសំរាប់ពាក់លើមួក**

-រូបព្រះសង្ហារយកតាមសញ្ញាជាតិ ធ្វើពីលោហធាតុពណ៌មាសនៅលើវល្លិព្រះសង្ហារ មានសរសេរអក្សរ **ព្រះចៅក្រុងកម្ពុជា** សំរាប់ពាក់លើមួកកាសស្កេត និងមួកស៊ីកាស ទំហំ កំពស់ ៧.៨ ស.ម ទទឹង ៦.៥ ស.ម សំរាប់ពាក់លើមួកបោណេ ទំហំ កំពស់ ៥ ស.ម និងទទឹង ៤ ស.ម

-រូបព្រះសង្ហារយកតាមសញ្ញាជាតិ ធ្វើពីអំបោះពណ៌មាស ប៉ាក់ភ្ជាប់នឹងមួកហ្សិកកី មួកហាមចំផ្នែកខាងមុខ និងមួកបេរេ នៅខាងមុខផ្នែកខាងស្តាំ ទំហំ កំពស់ ៥ ស.ម និង ទទឹង ៤ ស.ម ។

**២-ផ្លាកសញ្ញាសំរាប់ថ្នាក់ឧត្តមសេនីយ៍**

-ផ្លាកសញ្ញាសំរាប់ថ្នាក់ឧត្តមសេនីយ៍ គ្រប់លំដាប់ថ្នាក់មានតែមួយប្រភេទ ។

-រូបសញ្ញា ៖ ផលិតអំពីលោហធាតុពណ៌មាសមានរាងដូចស្លែងក្របី ផ្នែកខាងលើមានម្កុដ តំណាងឱ្យប្រជាជាតិខ្មែរ ផ្នែកខាងក្រោមមានលំពែងស្នាយសត្វ និងយុត្ថាតំណាងឱ្យកងទ័ពទាំងបីប្រភេទ ។ សញ្ញាផលិតអំពីក្រណាត់ពណ៌ខ្មៅ មានប៉ាក់រូបដូចខាងលើពីអំបោះពណ៌មាស សំរាប់ពាក់លើឯកសណ្ឋានប្រយុទ្ធ ។

-ខ្នាត ៖ -កំពស់រូបភាព ៤ ស.ម ទទឹង ៣ ស.ម

-កំពស់ម្កុដ ១.៨ ស.ម បាតក្រោមម្កុដ ១.៣ ស.ម

-កំពស់យុត្ថា ១.៦ ស.ម ចុងថ្លៃយុត្ថា ពីម្ខាងទៅម្ខាង ២ ស.ម

-កំពស់លំពែងដោយគិតពីដងយុត្ថា ០.៦ ស.ម

-ស្លាបសត្វរាងដូចស្លែងក្របី ម្ខាងមានស្លាប ៣ ជាន់ ( ជាន់ទី ១ = ១១ ស្លាប ទី២ = ៩ ស្លាប ទី៣ = ៧ ស្លាប ) កំពស់ ២៤ ម.ម ពីចុងម្ខាងទៅម្ខាង ៣៥ ម.ម ។

**៣- ឯកសណ្ឋានការងារលេខ ៤**

ក-ឯកសណ្ឋានការងារដៃខ្លី ៖

-ឯកសណ្ឋានការងារដៃខ្លី អាវពណ៌គ្រេអ៊ីកាត់ស្រុងដាក់ក្នុងខោ ហើយខោពណ៌គ្រេអ៊ី

-អាវដៃខ្លី ពណ៌គ្រេអ៊ីកខុប ប៊ូលស្មាសងខាង កាត់ស្រុងវែងដាក់ក្នុងខោ ហោប៉ៅពីរដេរប៉ះចំកណ្តាល ដេរបត់ផ្នត់មានគម្របរាងស្លឹកពោធិ ឡេវចម្មតាពណ៌គ្រេអ៊ី

- ខោជើងវែង ពណ៌គ្រេអ៊ីមានក្លីពីរ

- មួកបោណេ ឬមួកបេរេពណ៌គ្រេអ៊ី

-ខ្សែក្រវាត់តូចពណ៌គ្រេអ៊ី ដូចខ្សែក្រវាត់ឯកសណ្ឋានលេខ ១

ខ-ឯកសណ្ឋានការងារដៃវែង ៖

-ឯកសណ្ឋានការងារដៃវែង មានរូបភាព និងម៉ូតដូចឯកសណ្ឋានការងារដៃខ្លីខាងលើ តែមានដៃវែង នៅចុងដៃអាវមានឆែក និងដាក់ឡេវ

-ខោ មួកដូចឯកសណ្ឋានការងារដៃខ្លី

-ចំពោះនារី អាវដូចបុរស ខោជើងវែងកាត់ដូចបុរស ឡេវចំហៀង ឬសំពត់ហ្សីបមានឆែកកណ្តាលពីខាងក្រោយ ពណ៌គ្រេអ៊ីក្រោមជង្គង់ ។

* ឯកសណ្ឋានការងារលេខ ៤ នេះសំរាប់ពាក់ធ្វើការងារធម្មតាក្នុងការិយាល័យ ឬក្នុងបន្ទាយ និងទំនាក់ទំនងការងារធម្មតា ។

**ការស្លៀកពាក់** ៈពាក់អាវដៃខ្លី ឬដៃវែងពណ៌ត្រែអ៊ី នៅដៃអាវខាងស្តាំ ដាក់ផ្លាកកងយោធពលខេមរភូមិន្ទ និងនៅដៃអាវខាងឆ្វេងពាក់សញ្ញាផ្លាកកងឯកភាព ។ ខោជើងវែងពណ៌ត្រែអ៊ី ខ្សែក្រវាត់តូចពណ៌ត្រែអ៊ី មួកបេរ៉េពណ៌ត្រែអ៊ី មានរូបព្រះសង្ហារនៅខាងមុខផ្នែកខាងស្តាំ និងមានសញ្ញាសក្តិនៅខាងមុខផ្នែកខាងឆ្វេង ឬមួកបេរេពណ៌ត្រែអ៊ី ស្បែកជើងស្បែកកខ្លីពណ៌ខ្មៅ និងស្រោមជើងខ្មៅ ។ ពាក់សញ្ញាប្រភេទទ័ព នៅកអាវផ្លាកឈ្មោះនៅខាងលើហោប៉ៅអាវស្តាំ ហានុមានពាក់នៅនឹងឡេវហោប៉ៅអាវស្តាំសក្តិនៅលើស្មា ដែលមានហ្វុងសក្តិខ្មៅក្បាលស្រួច និងពាក់មេដាយ អាវជានិច្ចកាលត្រូវដាក់ក្នុងខោ ។ ចំពោះកងនាវាចរ និងអាកាសចរ ត្រូវស្លៀកពាក់ឯកសណ្ឋានការងារតាមការកំណត់ខាងលើ ហើយពាក់គ្រឿងរូមផ្សំផ្សេងៗទៀត និងរបៀបប្រើប្រាស់ដូចទ័ពជើងគោក តែកងអាកាសចរ និងបណ្តាកងឯកភាព ដែលមានសញ្ញាលើហោប៉ៅអាវស្តាំ លើផ្លាកឈ្មោះត្រូវពាក់ថែមទៀត ។

ចំពោះរូបភាពនៃឯកសណ្ឋានការងារដៃខ្លី និងដៃវែងមានគំរូក្នុងឧបសម្ព័ន្ធថ្មី នៃអនុក្រឹត្យនេះ ។

**មាត្រា២.-**

ត្រង់ចំណុច ក មាត្រា៥ និងត្រង់ចំណុចទី ១ ទី ២ មាត្រា ៦ នៃអនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៧ និងត្រង់ចំណុច ៣ មាត្រា ១ នៃអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៣ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ និងក្រសួងស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

**សហរដ្ឋមន្ត្រីក្រសួងការពារជាតិ**

**ទៀ បាញ់ ញឹក ប៊ុនឆៃ**

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធថ្មី

នៃអនុក្រឹត្យលេខ៧១ អនក្រ.បក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៤

**១/ខោអាវការងារ** ( ខោជើងវែងមានជីបភ្លីពីរទាំងសង្ខាង ) **និង មួកបេរ៉េ**



**២/មួកហ្សីកគី + ព្រះសង្ការ**

